ខ្មែរប៉ុស្តិ៍
ស.វ.អា
# KhmerPost USA
Printing The Cambodian World News
VOL. 05 ISSUE 85 June 17th - 30th, 2011

សុបិន : (267) 253-3947, សែម : (781) 244-0522

MASSACHUSETTS
217 APPLETON ST.
LOWELL, MA 01852
PENNSYLVANIA
438 LINDLEY AVE.
PHILADELPHIA, PA 19120
RHODE ISLAND
NEW JERSEY

**មាតិការឿង** **ទំព័រ**

១- កាត់បុគ្គលិកសិក្សាព្រោះគ្មានថវិកា..........០៣
២- ស្វែងយល់អំពីរបបផ្តាច់ការ..........០៤
៣- ជូនចំពោះលោកអ្នកសប្បុរសជន..........០៥
៤- បណ្តាប្រទេសឧស្សាហកម្មខ្ពស់..........០៦
៥- ញត្តិគាំទ្រគណបក្សសិទ្ធិមនុស្ស..........០៧
៦- The Cambodia Daily..........០៨ & ១៣
៧- បញ្ហាទម្ងន់ងាយស្រួលដូចបកចែក..........០៩

# ទិវាសម្រាប់ឪពុក
# HAPPY FATHER'S DAY

...ថ្ងៃទិវាសម្រាប់ឪពុក ២០១១នេះ ខ្មែរប៉ុស្តិ៍សូមឧទ្ទិសដល់គ្រប់ឪពុកទាំងអស់ ដែលបានប្រឈមមុខនឹងឧបសគ្គគ្រប់យ៉ាង ដើម្បីការធំធាត់ និងរីកចំរើនរបស់កូនអស់រយៈពេលដ៏យូរ ដោយគ្មានត្អូញត្អែរ សូមឱ្យលោកឪពុកទាំងនោះ នៅតែជាបិតា និងជាស្វាមីដ៏ល្អប្រសើរបំផុតរបស់គ្រួសារជាទីស្រឡាញ់ ។




ខ្មែរប៉ុស្តិ៍ មានឪពុក៦រូបនេះ មិនត្រឹមតែជាឪពុកដ៏ប្រសើរសម្រាប់គ្រួសារខ្លួនទេ តែជាអ្នកជួយជ្រោមជ្រែង ជាគំរូឱ្យខ្មែរប៉ុស្តិ៍ផ្សព្វផ្សាយដំណឹងល្អៗដល់គ្រួសារឯទៀតៗជាច្រើនផង ។

**សូមរីករាយទិវាសម្រាប់ឪពុក !!!**

Dear all fathers,

Enjoy the day to celebrate your fatherhood!

"The roles of dads evolve and change as our children change and as we dads change. There is no one right way to be a father and good fathering can look very different from one man to the next."

# សហគមន៍ខ្មែរត្រូវក្រសួងអប់រំមើលស្រាល

**ហ្វីឡាដែលហ្វៀ** : ស្ថិតិសិស្សនៅវិទ្យាល័យនានាដែលចែកផ្សាយដោយស្គូលឌីស្ត្រីកចុងក្រោយបង្អស់បានបង្ហាញថា សិស្សានុសិស្សខ្មែរ ដែលរៀននៅហ្វីឡាដែលហ្វៀនេះ មានចំនួន ១០២០នាក់ បើប្រៀបធៀបនឹងស្ថិតិបួនឆ្នាំមុន មានដល់ទៅជាង៤០០០នាក់ នៅលើចំនួននេះ គ្រូបង្រៀន១១នាក់នៅក្នុងចំណោម ១៤នាក់ បានត្រូវបោចចោលដូចស្មៅ នេះជាស្ថានភាពនៃការគាំទ្រសកម្មភាពអប់រំកូនចៅសហគមន៍ខ្មែរនៅហ្វីឡាដែលហ្វៀ ដែលបានសង្កេតឃើញ នាឱកាសប្រជុំក្រុមអ្នកផ្តល់យោបល់ស្តីអំពីការអប់រំរបស់សហគមន៍ខ្មែរ កាលពីថ្ងៃសុក្រ ទី១០ មិថុនាកន្លងទៅនេះ (តទៅទំព័រទី ០៣)



បុគ្គលិកសិក្សាខ្មែរតវ៉ានៅមុខ School District កាលពីថ្ងៃច័ន្ទ ទី១៣ ខែមិថុនា

PTW ការិយាល័យព្យាបាលរាងកាយ
Physical Therapy of Woburn
Retrey Khun 617-980-4356
ព្យាបាលឈឺខ្នង គ្រោះថ្នាក់រថយន្ត និងស្ត្រីឈឺខ្លួនពេលមានគភ៌
សេវាបំរើនៅតំបន់ Lynn, Revere, Lowell, Lawrence
យើងនិយាយភាសាខ្មែរ
400 West Cummings Park, Suite 1400. Woburn, MA 01801
www.ptwoburn.com

ហាងមាសខ្មែរអង្គរ
KHMER ANGKOR JEWELRY
Since 1983
Certified Diamonds & Diamond Jewelry



18K & 24K Gold, Platinum Jewelry & Watches
GIA Graduate Gemologist on Staff
Authorized RADO & LONGINES Dealer
Repairs Done on Premises
Open Tuesday-Sunday 10:30AM-6:30PM Closed Monday
600 Washington Avenue. Unit 12B. Philadelphia, PA 19147
Tel. 215-599-2222 Fax. 215-599-2223

# GATEWAY FAMILY DENTAL

## NOW OPENED AT GATEWAY CENTER II (978) 455-5044

**151 WARREN STREET, SUITE 120 LOWELL, MA 01852**
**(Same building as Social Security/near the courthouse)**



### DR. SERENA B. CHUOP

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.

**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វីរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

**MOST DENTAL INSURANCES ACCEPTED INCLUDING MASSHEALTH FOR KIDS FINANCING AVALIABLE**

**យើងទទួលនូវគ្រប់ អ៊ិន ស៊ូរ៉ន Masshealth for Kids យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ**

**CALL FOR YOUR FREE CONSULTATION (978) 455-5044**

**www.gatewayfamilydental.com**

# កាត់បុគ្គលិកសិក្សាព្រោះគ្មានថវិកា


កិច្ចគ្រូបង្រៀនខ្មែរនៅវត្តព្រះពុទ្ធរង្សី

**ហ្វីឡាដែលហ្វៀ** : ថវិការបស់ក្រសួងអប់រំ (School District) នៅហ្វីឡាដែលហ្វៀ ត្រូវបានជយចុះចំនួន ៦២៩លានដុល្លារ ដូច្នេះបង្ខំឱ្យក្រសួងមួយនេះ បន្ថយចំនួនបុគ្គលិកខ្លួនប្រមាណ ៥០០០នាក់ ក្នុងនោះមានក្រុមគ្រូបង្រៀនចំនួន ១៥០០នាក់ និងបុគ្គលិកប្រចាំក្រសួងប្រមាណ ៥០០នាក់ទៀត ។

ការបន្ថយចំនួនបុគ្គលិកសិក្សាដ៏ច្រើនលើសលប់នេះ បានត្រូវទទួលការទិទានថា នឹងប៉ះពាល់យ៉ាងដំណំនូវគម្រោងកែទម្រង់វិស័យសិក្សាធិការនៅហ្វីឡាដែលហ្វៀ ដែលកំពុងតែទទួលផ្លែផ្កាប្រសើរនាឆ្នាំកន្លងទៅនេះ ។ ការកាត់បន្ថយនេះគឺសម្របទៅតាមឱនភាពរបស់សហរដ្ឋអាមេរិក ដែលចេះតែស្រុតចុះដាបទៅជាមួយនឹងសង្គ្រាមនៅមជ្ឈិមបូព៌ា ហើយនឹងតម្រូវទៅតាមការកែទម្រង់របស់ក្រសួង ដែលត្រៀមផ្លាស់ប្តូរឱ្យបានចប់សព្វគ្រប់នៅឆ្នាំ២០១៤។

គ្មានសល់អ្វីដូចមុនទៀតទេ សម្រាប់ក្រសួងអប់រំនៅហ្វីឡានេះ សហគមន៍ខ្មែរបានឃើញក្រុមគ្រួសារខ្លួនចូលកាន់តំណែងនានាមួយចំនួនកាលពី១ឆ្នាំ ឬពីរឆ្នាំមុន ឥឡូវនេះអាចនឹងទទួលលិខិតបញ្ចប់កិច្ចសន្យាដោយសារខ្លួនចូលមកដល់ក្រសួងនេះក្រោយគេឥឡូវអាចនឹងត្រូវចេញទៅវិញក៏មុនគេដែរ គួរឱ្យស្តាយ ! ថែមពីនេះ ក៏គ្មានអ្វីធានាថា ឱនភាពនឹងឈប់ស្រុតចុះតទៅទៀតដែរ ។ អ្នកវិភាគសេដ្ឋកិច្ចនិយាយថា ពួកគេពុំទាន់ឃើញសញ្ញាណាមួយដែលចង្អុលថា សេដ្ឋកិច្ចសហរដ្ឋអាមេរិកនឹងងើបឡើង រួចមុន៥-១០ឆ្នាំទៅមុខនេះទេ ។

ប្រឈមមុខនឹងស្ថានភាពសង្គមខ្មៅងងឹត តើសហគមន៍ខ្មែរ មានបានត្រៀមខ្លួន រៀបគម្រោងពិគ្រោះគ្នា ដើម្បីទប់ទល់នឹងវិបត្តិដែលកំពុងជោរជន់យ៉ាងជាក់ស្តែងមកលើសហគមន៍ខ្លួនឯង គ្រួសារខ្លួនផ្ទាល់ដែរឬទេ ? គំរូនៃឱនភាពថវិការដ្ឋ គេរៀបចំកាត់កង គឺតគួរកុំឱ្យរលំដោយចៃដន្យ ក៏ប៉ុន្តែកូនចៅខ្មែរ ដែលនៅកំពុងតែរៀនសូត្រ និងមានផលប៉ះពាល់រីតតែធ្ងន់ប៉ុណ្ណា ? អ្នកស្រី វ៉ង ស៊ន នាយិកាសមាគម និយាយថា "វាទាល់តែថ្នាក់ដឹកនាំនៃសហគមន៍ខ្មែរ នាំគ្នាចាប់អារម្មណ៍ឱ្យខ្លាំងទៅលើវិស័យអប់រំកូនខ្មែរនេះ ហើយវត្តអារាមក៏មានតួនាទីធំណាស់ដែរក្នុងការណែនាំមាតាបិតានៃសហគមន៍ឱ្យគាំទ្រវិស័យអប់រំគ្រួសារខ្មែរ ឱ្យមានអនាគតភ្លឺស្វាងផងទើបបាន" ៕ *(ខ្មែរប៉ុស្តិ៍)*

# តមកពីទំព័រទី ០១ សហគមន៍ខ្មែរត្រូវក្រសួងអប់រំ...

ហើយក្នុងនោះមានបុគ្គលិកអប់រំ និងឯកជនប្រមាណ ២០នាក់ចូលរួម ។

អង្គប្រជុំបានឱ្យដឹងថា ក្នុងស្ថិតិនោះមានការកត់ត្រាខុសជាច្រើនអន្លើគួរឱ្យសោកស្តាយមានសាលាខ្លះកូនសិស្សខ្មែរនៅពេញតែពុំមានឃើញចុះបង្ហាញថា មានសិស្សខ្មែរទីនោះទេ ។ ប្រៀបធៀបទៅនឹងការបញ្ឈប់បុគ្គលិកទៅតាមសញ្ជាតិ និងវប្បធម៌ ឃើញថា ដែលមានភាពអយុត្តិធម៌រីតតែខ្លាំងទៅទៀត ដោយបុគ្គលិកខ្មែរដែលឈប់ដោយចូលនិវត្តន៍ ឬប្រការផ្សេង ពុំបានត្រូវគេប្តូរបុគ្គលិកថ្មីជំនួសនោះទេ តែបើងចិន និងវៀតណាមមានបុគ្គលិកថ្មីចូលហូរហែរ ថ្វីត្បិតតែស្ថានភាពថវិកាមានឱនភាពដូចគ្នាដែរ ។ ចំណែកឯពាក្យថា ការកាត់បុគ្គលិកខ្មែរ៥០% ក៏ខុស ទៅទៀត ពីព្រោះពេលនេះឈ្មោះដែលត្រូវដក ចេញមានរហូតដល់ជិត ៨០% ឯណោះ ។


Jerry ប្រធានសហជីពបុគ្គលិកសិក្សា

សហគមន៍ខ្មែរដែលនាពីរឆ្នាំចុងក្រោយនេះចេញមុខតវ៉ាទាមទារឱ្យក្រសួងអប់រំបង្កើតបុគ្គលិកដែលអាចជួយដោះស្រាយគ្រួសារខ្មែរ ពីបញ្ហាសិក្សារបស់កូនចៅដែលបានធ្លាក់ដុនដាបជាខ្លាំងនោះ បានផ្តល់ចម្លើយគួរកក់ក្តៅបានខ្លះ ហើយក៏ប៉ុន្តែដំណោះស្រាយដូចដែលបានបង្ហាញពេលនេះ ហើយនឹងធ្វើឱ្យសហគមន៍ខ្មែរត្រឡប់ទៅជួបវិបត្តិសិក្សាធិការនេះរីតតែធ្ងន់ធ្ងរជាងមុនទៅទៀត ។

សហជីពគ្រូបង្រៀនបានតវ៉ាយ៉ាងពេញទំហឹងចំពោះបុគ្គលិកសិក្សា៥០០០នាក់ភ្លាមឱ្យឈប់ពីការងារយ៉ាងទាន់ហន់មិនដែលមានពីមុនមក... រីឯសហគមន៍ខ្មែរពុំទាន់ឃើញមានប្រតិកម្មណាមួយចំពោះវាស្នាគ្រូបង្រៀនខ្មែរដែលទើបតែបាត់បង់ការងារខ្លួននៅឡើយទេ ៕ ***(ខ្មែរប៉ុស្តិ៍)***


## និទាឃរដូវ គឺជាពេលវេលាមួយដ៏ប្រសើរសម្រាប់ការឈប់ជក់បារី !

- **ផលល្អនៃការឈប់ជក់បារីមួយចំនួន :**
- ភាពប្រឈមមុខនឹងជំងឺមហារីក និងជំងឺបេះដូងថយចុះ
- សកម្មភាពប្រចាំថ្ងៃមិនធ្វើឱ្យលោកអ្នកចង់ផុតដង្ហើម (ដូចឡើងកាំជណ្តើរ) ទៀតផង
- ខ្យល់ដកដង្ហើមមានក្លិនល្អជាងមុន
- ម្រាមដៃ និងក្រចកដៃមើលទៅមិនមែនពណ៌លឿងទៀតទេ
- ញាណហិតក្លិនវិលត្រឡប់មកដឹងក្លិនដូចធម្មតាវិញ
- ម្ហូបមានរសជាតិឆ្ងាញ់ជាងមុន



**មូលហេតុមួយចំនួនសម្រាប់ការឈប់ជក់បារី :**
- ការជក់បារីអាចបណ្តាលឱ្យមានបញ្ហាក្នុងការដកដង្ហើម ហើយអាចបង្កឱ្យជំងឺហឺត និងរោគរលាកសួតកាន់តែដុនដាប ។
- ការជក់បារីក៏អាចបង្កឱ្យមានជំងឺបេះដូង និងជំងឺដាច់សរសៃឈាមក្នុងខួរក្បាលផងដែរ ។
- ការជក់បារីបណ្តាលឱ្យមានជំងឺមហារីកសួត មហារីកបំពង់អាហារ មហារីកដើមបំពង់ក (ប្រអប់សម្លេង) មហារីកមាត់ មហារីកបំពង់ក មហារីកតម្រងនោម មហារីកផ្លោកនោម មហារីកផ្ចាល មហារីកក្រពះ និងមហារីកកស្បូន ។

# HELP WANTED

KhmerPost USA is seeking local contributed writers from Lowell area in both Khmer & English. No previous journalism experience is required.Since 2008, KhmerPost Newspaper has been incepted and served Cambodian communities in the East Coast of United States from Pennsylvania, to New Jersey, to Rhode Island, and now, since August 2010, we have been serving the State of Massachusetts. We are now covering entirely Lowell, Lynn, Revere, and will expand to Fall River. To help improve our content, we will need the participation from your community by feeding us the information about what's happening within your neighborhoods. Whether you are a college student, afull-time mom, or working professional, who just want to share news and information from your community to the rest of Cambodian communities, please don't hesitant to contact us.




Our Contact:
Roger Samkhon Pin
Publisher & Editor-in-Chief
pinsamkhon@gmail.com
or by Mail
438 Lindley Avenue.
Philadelphia, Pa 19120

# ស្វែងយល់អំពីរបបផ្តាច់ការនៅប្រទេសយេម៉ែន

*យេម៉ែន កំពុងរងការរំជើបរំជួលយ៉ាងខ្លាំងក្លាពីសំណាក់ប្រជាជនប្រឆាំងនឹងប្រធានាធិបតីរបស់ខ្លួន ។*

**ប្រែសម្រួលដោយ : តិច វិចល**

•••អាលីអាប់ដាឡាហ៍ សាឡិច (Ali Abdallah Saleh) ប្រធានាធិបតីបច្ចុប្បន្ននៅយេម៉ែន ពិតជាបានពង្រឹងវាសនារបស់គាត់លើផ្ទៃប្រទេសដែលក្រីក្រជាទីបំផុត និងដែលពោរពេញទៅដោយបក្សពួកជិតស្និទ្ធបំផុត ដែលជាក្លូង់ ។

បន្ទាប់ពី ហ្គាដាហ្វី ជនផ្តាច់ការទី២នេះ បានដឹកនាប្រជាជាតិយេម៉ែន ឱ្យប្រឈមមុខទល់នឹងភាពក្រីក្រ ភាពហឹង្សាជាអចិន្ត្រៃយ៍ ភាពពុករលួយ និងហ្វូងបក្សពួកមួយចង្កោមដែលរក្សាទប់កៅអីអំណាចលើប្រទេសយេម៉ែន ។ គេតែនិយាយថា ប្រទេសយេម៉ែនជា "ប្រទេសសម្បូរណ៍ទៅដោយកាំភ្លើងប្រយុទ្ធកាឡាស់នីកុហ្វ (Kalashnikoff) ច្រើនជាងចំនួនប្រជាជនក្នុងប្រទេស" ។

តាមឯកសារព័ត៌មានអន្តរជាតិ គ្រួសាររបស់សាឡិច ពុំមានទ្រព្យសម្បត្តិ ឬគុណធមិវិជ្ជាអ្វីល្អប្រសើរក្នុងប្រទេស ។ តាំងពីកំណើតគាត់មក គាត់មានចំណេះវិជ្ជាដំទាបមុននឹងឈានចូលកៅអីអនុវិទ្យាល័យ ។ គាត់កើតក្នុងវង្សក្លូង់ (Clan) តូចមួយដែលភ្ជាប់ខ្លួនទៅក្លូង់ហាស្សិត (Hached) នៅតំបន់ភាគខាងជើងប្រទេស ។ រីឯភាគខាងត្បូង ដែលកំពុងរងចលាចលរវាងក្រុងសាធារណនិយម គាំទ្រដោយ ណាស់សែ (Nasser) (បទេសអេហ្ស៊ីប) និងក្រុមប្រកាន់អេម្បៀ (Emir) ដែលគាំទ្រដោយអារាប់ប៊ីសេអ៊ូឌីត ។ ភាគខាងជើងប្រទេស ត្រូវបានគ្រប់គ្រងដោយអាណានិគមអង់គ្លេស ដែលបានដកចេញតាំងពី ១៩៦៨ ។

សាឡិច រត់ចូលជាមួយ ក្លូង់ហ្សាឌីត (សាធារណនិយមខាងលើនេះ) ។ ក្លូង់ហ្សាឌីត នេះគឺជាក្លូងនយោបាយចំបងមួយប្រឆាំងនឹងអង់គ្លេសនៅក្នុងប្រទេស ។

ប្រជារាស្ត្រយេម៉ែន តែងនិយាយថា សាឡិច មានមាឌតូចច្រឡឹង តែពុំមានវប្បធម៌ក្នុងខ្លួន ឬ រៅហាជាអ្នកដឹកនាំខ្នាតធម្មតាទេ ជាលេសដែលក្រុមអេម្បៀរ អារ៉ាប់ប៊ី តែងតែស្អប់ពុំចូលចិត្តឡើយ ។ រាល់សម្ភាសន៍ ដែលផ្តល់ឱ្យកាសែត ចម្លើយរបស់គាត់មិនដែលមានន័យរយៈពេលស្មើទៅសំនួរម្តងណាទេ ។

ក្រុមអ្នកង្កេតការណ៍អន្តរជាតិ តែងរៀបរាប់គាត់ក្នុងចំណោមប្រធានាធិបតីអារ៉ាប់ផ្សេងៗ ដូចជា ប៊ូម៉េឌីយែន (Algeria), ណាស់សែ (Nasser), អាល់ អាស្សាដ (Al Assaab) ឬក៏ សាដាំហ៊ុសសេន (Sadam Hussein) ជាដើម ។

នៅឆ្នាំ ១៩៧៤ សាឡិច បានធ្វើរដ្ឋប្រហារផ្តួលបក្ស អេម្បៀរនិយមអារ៉ាប់ប៊ី ជារៀងរហូតមក ។ បួនឆ្នាំបន្ទាប់មក គាត់បានលួចសម្លាប់ អាហ៍ម៉ែត បិនហ៊ុសសេន អាល់ហ្គាហ្ស៊ី (Ahmed Ben Hussein Al Ghachmi) ដែលជាប្រធានាធិបតីដំបូងនៃប្រទេសយេម៉ែន មានទាំងទាហានជាន់ខ្ពស់ចំនួន៣០នាក់ទៀតផង កាលពីជំនាន់នោះ សាឡិច បានក្លាយជាប្រធានកងយោធាជាតិ និងជាប្រធានមហាសន្និបាតរាស្ត្រនិយមមួយទៀតផង ។



មនុស្សដែល សាឡិច តែងតែយកគំរូតាម គឺ សាដាំហ៊ុសសេន (Iraq) ដែលបានក្លាយជាឧបជ្ឈាដ៏ល្អប្រពៃរបស់គាត់ ។

សេចក្តីអត្ថាធិប្បាយខាងលើនេះ បញ្ជាក់ថា ប្រធានាធិបតីយេម៉ែន លោកសាឡិចនេះ ពុំមានយុទ្ធសាស្ត្រនិយមច្បាស់លាស់ទេក្នុងការដឹកនាំប្រទេស តែ សាឡិច ជាមនុស្សដែលឆ្លាតពោរពេញទៅដោយល្បិចរហ័សតាមសភាពការនយោបាយ ។ បន្តមកទៀត គេឃើញ សាឡិច ក្លាយជាមិត្តរបស់អ៊ីរ៉ង់ អារ៉ាប់ប៊ីសេអ៊ូឌីត និងប្រទេសសូវៀតទៀតផង ។ ជាពិសេស ក្នុងយុទ្ធសាស្ត្រប្រឆាំងភេរវកម្មអាល់កៃដា សាឡិច បានទទួលការទុកចិត្តពីសហរដ្ឋអាមេរិកយ៉ាងខ្លាំងក្លាទៀតផង ។

កាលពីអំឡុងសង្គ្រាមអ៊ីរ៉ាក់ (១៩៩០-៩១) នៅពេលដែលមានការឈ្លានពានប្រទេសសូវៀត (Arabie Seoudite) ដោយ (Iraq) នោះ គេឃើញ ប្រធានាធិបតី សាឡិច នេះ សរសើរទទួលគាំទ្រ Sadam Hussein (Iraq) យ៉ាងមុតមាំបំផុត ។ វាក៏ដូចគ្នានេះដែរ ពោលគឺភូមិភាគយេម៉ែនខាងត្បូង ត្រូវបាន សាឡិច រៀបចងសម្ព័ន្ធភាពជាមួយប្រទេសសូវៀត ដោយបង្កើតរបបគ្រប់គ្រងបែបសង្គមនិយមសូវៀត លើទូទាំងភូមិភាគនេះតែម្តង ជាហេតុបង្កើតឱ្យមានសភាពការណ៍តានតឹងផ្នែកនយោបាយរវាងភាគខាងត្បូង និងភាគខាងជើង ក្រោយពីអង់គ្លេសដកថយចេញ (១៩៦៨ មកម្ល៉េះនោះ) ។ មិនតែប៉ុណ្ណោះ សាឡិច ពុំខ្លាចក្រឡាប់ចាក់នាឆ្នាំ១៩៩៤ ក្បត់មិត្តភាពដែលធ្លាប់មានជាមួយសម្ព័ន្ធអ៊ិស្លាមនៃក្លូង់របស់ឆែក (Cheikh) Al Ahmar ។

ក្រោយពីបានជាប់ឆ្នោតនៅឆ្នាំ ១៩៩៩ (Suffrage Direct) សាឡិច កែប្រែរដ្ឋធម្មនុញ្ញគ្រប់គ្រងពី៥ឆ្នាំ-៧ឆ្នាំ ហើយតែងតាំងខ្លួនឯងជាអគ្គប្រមុខសេនានៃរី (Marechal) លើទូទាំងប្រទេសរបស់គាត់ ។

បច្ចុប្បន្ននេះ គេកំពុងសង្ស័យលើការរៀបចំឱ្យបន្តអំណាចគ្រប់គ្រងដោយកូនប្រុសម្នាក់ AHMED នៅពេលដែលកូនប្រុសម្នាក់ទៀតឈ្មោះ ALI ជាអគ្គនាយកសន្តិសុខជាតិ រួមជាមួយក្រុមក្ដួយៗជាច្រើនទៀត ។ លោក សាឡិច (ALI ABDALLAH SALEH) ជាប្រធានាធិបតីដែលមានសំណាងបានបង្ហាញនូវភាពយង់ឃ្នងក្នុងការគ្រប់គ្រងប្រទេសដោយពុំបាច់ ដោយផ្អែកលើបក្ស ក្លូង់អរិជ្ជាតែម្នាក់ក្នុងពិភពលោក ៕


East Coast Center

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist

Joseph A. Russo, M.D. F.A.C.S

Plastic & Reconstructive Surgeon

www.eastcoastsurgery.com




ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត

381 West Broadway South Boston, MA 02127

(617) 464 - 0001

ភោជនីយដ្ឋាន ណាម វាង (ភ្នំពេញ)

Nam Vang Restaurant

571 Unit#1 Adams Svenue. Philadelphia, PA 19120

(inside Hong Kong Market) (215) 742-9488





រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់ប្រភេទផ្លែឈើ ដូចជា: ទុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅស្រស់ៗ

១_មុខជំនាញខាងម្ហូបខ្មែរ យ៉ាងចំណាន ដូចជា :
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ទាំង ឆាសាច់គោ
- មីកន្ទាំងឆាគ្រឿងសមុទ្រ
- បាយឆាគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

២_មុខជំនាញម្ហូបវៀតណាម ល្បីឆ្ងាញ់ ដូចជា :
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉័ងប៉ាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬ មី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

Open 7 days a week from 9a.m-9p.m

បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច

# ជូនចំពោះលោកអ្នកសប្បុរសជនជួយដល់កុមារកំព្រានៅកម្ពុជា

**ពិន សំខុន រ៉ជែរ**

...ជំរំកុមារកំព្រា CCPSO ដែលខ្ញុំបានឧបត្ថម្ភឱ្យបានកើតឡើងកាលពីឆ្នាំ១៩៩៦ នៅជាយពោធិ៍ចិនតុងដែលចិញ្ចឹមក្មេងកំព្រា៣៤នាក់ (អាយុពីតិចជាងមួយខែ ដល់១១ឆ្នាំ) មានដំណើរការល្អប្រពៃរហូតមកដល់ថ្ងៃនេះ ជាមួយនឹងជំរំតូច៧២ទៀត : ១នៅជិតក្រុងកំពង់ធំ មានក្មេង១១នាក់ និងមួយទៀត នៅក្រុងកែប មានក្មេង៥នាក់ ។ ចូលរួមជាមួយនឹងខ្ញុំនាពេលនោះ ដោយការស្ម័គ្រចិត្តនៃក្រុមអតីតអ្នកការពារក្តីអមតុលាការ ធ្លាប់ជួយការពារផ្នែកច្បាប់អ៊ិនតាក់ ដល់ពលរដ្ឋដោយមិនយកកម្រៃ ហើយដែលបានទទួលការបញ្ចប់ក្របខណ្ឌពីរដ្ឋាភិបាលនៅឆ្នាំ១៩៩៥ មជ្ឈមណ្ឌលកុមារកំព្រាចំនួនបីក៏បានកើតឡើង បើទោះបីធ្លាប់ជួបប្រទះឧបសគ្គចំបងច្រើនយ៉ាងណាក្តី ។

ខែកក្កដា ឆ្នាំ១៩៩៧ ខ្ញុំបានចាកចេញពីកម្ពុជានាឱកាសចលាចលដោយរដ្ឋប្រហារមួយទៅកាន់ប្រទេសថៃ រួចក៏បានមកដល់សហរដ្ឋអាមេរិក តែបានណែនាំការងារ និងថវិកាបន្តដោយសមាគម «សម្រស់ភក្ត្រាកុមារខ្មែរ» ជាក្រុមជំនួយសប្បុរសមកពីស្រុកបារាំងវិញម្តង ។ កុមារកំព្រាជាច្រើនបានរស់នៅធំធាត់ សិក្សារហូតបានចេញទៅធ្វើការដោយការគ្រប់គ្រងទិញដៅ «សមាគមសម្រស់ភក្ត្រាកុមារខ្មែរ» នឹងដោយការថែទាំផ្ទាល់ដៃយ៉ាងផ្ចិតផ្ចង់របស់នាយកជំរំ អតីតអ្នកការពារក្តីរហូតដល់សព្វថ្ងៃនេះ ហើយថែមទាំងពង្រីកទំហំទីជម្រក និងទទួលកុមារថ្មីៗបានទៀតផង ។

លោកអ្នកនាងជាសប្បុរសជនជាទីគោរព ! ស្ថានភាពសេដ្ឋកិច្ចសកលលោកអន់ថយ ថវិកាទ្រទ្រង់ប្រមូលចូលបានតិចតួច ដូច្នេះខ្ញុំសូមអញ្ជើញបងប្អូនញាតិមិត្ត ដែលធ្លាប់តែមានចិត្តសប្បុរស ហើយមិនអាចមើលរំលងវាសនាកុមារកំព្រាខ្មែរតែនឹងភ្នែក សូមមេត្តាយកទឹកចិត្តដោយធម៌នោះ ជួយធ្វើការបរិច្ចាកទាន ទោះតិចក្តី ច្រើនក្តី ដើម្បីរក្សាជំរំក្មេងកំព្រាទាំងនោះ ឱ្យនៅគង់វង្សតទៅមុខបាន ។ តំណាងឱ្យកុមារកំព្រាខ្មែរទាំងអស់ សូមអរគុណទុកជាមុន ៕



ជំរំកុមារកំព្រា CCPSO នៅជាយពោធិ៍ចិនតុង ឆ្នាំ២០០១

**វិភាគទានស្ម័គ្រចិត្តសម្រាប់ជួយកុមារកំព្រាខ្មែរ**

**« សមាគមសម្រស់ភក្ត្រាកុមារខ្មែរ សហរដ្ឋអាមេរិក -ESK-USA »**

ខ្ញុំឈ្មោះ :..............................................................................................

អស័យដ្ឋាន :..........................................................................................

ទូរស័ព្ទ :..........................................អ៊ីម៉ែល.............................................

- ខ្ញុំស្ម័គ្រចិត្តធ្វើវិភាគទានប្រចាំខែ ចំនួន......................ខែ បង់មួយខែ........................ដុល្លារ
- ខ្ញុំស្ម័គ្រចិត្តធ្វើវិភាគទានតែម្តងនេះទេ ខ្ញុំសូមជូន...................................................ដុល្លារ
- ខ្ញុំស្ម័គ្រចិត្តធ្វើវិភាគទានជារបស់ប្រើប្រាស់:................................................(ឈ្មោះរបស់)
- ខ្ញុំស្ម័គ្រចិត្តធ្វើវិភាគទានជាពេលវេលា : សមាជិកស្ម័គ្រចិត្ត (ហត្ថលេខា)..........................

សូមលោកអ្នកនាង ទទួលនូវពរស្វាគមន៍ដ៏ស្មោះស្ម័គ្រអំពីខ្ញុំតំណាងឱ្យសមាគម "សម្រស់ភក្ត្រាកុមារខ្មែរ" និងសូមទទួលនូវការថ្លែងអំណរគុណដ៏ជ្រាលជ្រៅពីកុមារកំសត់ម្តាយឪពុកទាំងអស់ ។

ពិន សំខុន រ៉ជែរ

"E.S.K.-USA" Roger Samkhon Pin 438 Lindley Ave. Philadelphia, PA 19120 Phone : (267)254 8758


KhmerPost USA, LLC
East Coast Publication

**Pin Samkhon,**
*Publisher & Editor-in-Chief*
Email: pinsamkhon@gmail.com
*Staff Writers:* **Loeum Im, Audria Chea, Sovan Heng**

*Contributed Writers:*
**Mam Yin, Kim Phien, Lanica Angpak, & Dannely Sam**
KhmerPostLowell@gmail.com

**Soben Pin**
*Marketing Director*
KhmerPostUSA@gmail.com
**267-253-3947**
**Sam Khoeun**
*Sales Consultant*
**(781) 244-0522**

*Design Staffs:*
**Leang Heng & Doch Vuthy**
~~~~~

KhmerPost USA, LLC is an independent newpaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local, community, and national news; and give an insight into Cambodia & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Pennsylvanian & Massachusett.
~~~~

Semimonthly edition subscription is available within the U.S. & Canada at $60.00 and 70 Euros in Europe per year. Money order or check is accepted and made payable to:
KhmerPost USA, LLC
438 LINDLEY AVE.
Philadelphia, PA 19120
~~~


The Khmer Post has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009


ពេទ្យធ្មេញសំរាប់គ្រួសារ Caring Dental For ALL Ages




COMPLETE ផ្តល់គ្រប់សេវាកម្ម Services

- Cosmetic Dentistry
- Cosmetic Fillings
- Crowns & Bridges
- Dentures
- Extractions
- Implant Crowns
- Root Canal Therapy

- ត្រួតពិនិត្យទៀតទាត់ពេល
- សំអាតធ្មេញ
- ជំងឺចង្កោមធ្មេញ
- ដកសរសៃធ្មេញ
- ស្រោប-តម្រឹម និងប៉ះធ្មេញ
- ធ្វើធ្មេញឱ្យស
- បំពេញធ្មេញប្រហោង
- ដកធ្មេញ

Most Forms of Insurance & Payment
ACCEPTED ទទួលគ្រប់ អ៊ិនស៊ូរិន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

Convenient LOCATION
Next to Bank of America on Chelmsford Street




FREE Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 10/30/11

"EXCLUSIVE OFFER"
$55.00
Limited Time New Patient Special
(Regular Discount $55.99 a $250 Value)
Present coupon for discount, includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or insurance. Expires 10/30/11

យើងមានអ្នកនិយាយភាសាខ្មែរ អង់គ្លេស ស្ប៉ានីស និងវៀតណាម សូមទូរស័ព្ទ 978-455-4039 ដើម្បីណាត់ជួបនៅថ្ងៃនេះ

724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles-Dental.com
~~~

# បណ្ដាប្រទេសឧស្សាហកម្មខ្ពស់ "G-8" ពង្រឹងប្រជាធិបតេយ្យក្នុងតំបន់ទ្វីបអារ៉ាប់

**សម្រួលដោយ : គិច វិមល**

កម្លាំងទឹកប្រាក់ ជាចរន្តសរសៃឈាមក្នុងរក្សាសន្តិភាព ។ ជំនួយជាប្រាក់កម្ចីក្នុងរយៈពេលពាឆ្នាំប្រមាណ៧២កោដ្ឋដុល្លារ ត្រូវបានសម្រេចផ្ដល់ឱ្យដល់ប្រទេសទុយនេស៊ី និងអេហ្ស៊ីប ដើម្បីយកទៅប្រើសម្រាប់ប្រជាធិបតេយ្យក្នុងប្រទេសទាំងពីរនេះ ។ គោលឱ្យចំ G-8 មានបំណងចង់បានការពង្រឹងសេដ្ឋកិច្ចសេរី ក្រោមការដឹកនាំបែបប្រជាធិបតេយ្យ ។ កិច្ចប្រជុំ G-8 នេះបានប្រារព្ធធ្វើនៅឆ្នេរសមុទ្រដូវីល (DEAUVILLE - FRANCE) ។

គេសម្គាល់ឃើញមានយុទ្ធសាស្ត្រធំបងចំនួនបីដែលគេយកមកពិភាក្សាគ្នា : - សេរីរូបនីយកម្មសេដ្ឋកិច្ចដោយការប្រើប្រាស់ប្រាក់កម្ចី - បង្កបង្កើតរចនាសម្ព័ន្ធ និងមុខព្រួញទាំងឡាយក្នុងសេដ្ឋកិច្ចជាតិ ដែលត្រូវមានអធិភាពលើការនាំចេញក្រៅប្រទេស ។ ការបំបាត់ភាពពុំមានការងារធ្វើក៏នឹងអាស្រ័យលើប្រព័ន្ធសេដ្ឋកិច្ចនេះដែរ ។

សេរីរូបនីយកម្មសេដ្ឋកិច្ចនេះ និងបង្ហាញលំហសេដ្ឋកិច្ចមួយក្នុងការជម្រុញទ្វីបអារ៉ាប់ទាំងមូលអាចឈានទៅដល់ការលូតលាស់ ពោរពេញទៅដោយការងារធ្វើផ្ដល់ដល់ប្រជាជាតិគេទាំងមូល ។ បញ្ហាប្រទេសទាំងនេះ និងបង្កើតខ្លួនជាតំបន់ថ្មីមួយផ្នែកសេដ្ឋកិច្ចឱ្យនាំចេញ មិនខុសពីបណ្ដាប្រទេសអេមែកហ្សង់ (EMERGENT NATION COUNTRIES) អ្នកជំនាញអាមេរិកាំង កំណត់បានថា លើប្រជាជនប្រមាណ៤២០លាននាក់ក្នុងទ្វីបអារ៉ាប់នេះ កម្លាំងសេដ្ឋកិច្ចអាចមានស្មើប្រទេសស្វីសទាំងមូល ដែលមានប្រជាជនតែ៨លាននាក់ ។

នៅចំពោះមុខការនាំចេញ G-8 សង្ឃឹមថា ការដាក់អនុវត្តន៍ផែនការសេរីរូបនីយកម្មសេដ្ឋកិច្ចនេះ ត្រូវការនាំនូវប្រាក់មកពី IMF ប្រមាណ១/២ និងលើផ្នែកដំណោះស្រាយកិច្ចការទូតវិញ G-8 បានលើកយកមកពិភាក្សាណុវចំណុចក្ដៅគគក់ចំនួនបីករណី ៗ

- ប្រទេសលីប៊ី ពិសេសស្ដីពីបុគ្គល ហ្គាដាហ្វី
- ប្រទេសស៊ីរី ដែលបង្កើនល្បិចដង្ហូវស៊ីស្លឹកខ្ចី
- តំបន់ Leebanon / Israel.

ទាក់ទិននឹង ហ្គាដាហ្វី ដែលធ្លាប់បានសន្យាថាឈប់តបតការសម្លាប់រង្គាលលើពលទាហាន និងប្រជាជនដែលប្រឆាំងនឹងគាត់នោះ ហាក់ដូចជាបន្តសូត្រ និងច្រៀងចម្រៀងដដែលមកវិញ ផ្ដើនឱ្យ G-8 ពិសេស ដាវីតកាំរ៉ោន និង សាកូហ្ស៊ី ដែលជាអ្នកដឹកនាំដំបូងជាមួយប្រទេសអារ៉ាប់ ឱ្យអង្គការសហប្រជាជាតិ ចោទប្រកាន់លីប៊ី តាមវគ្គ ១៧៩៣ នៃការជួយស្រង់ជីវិត និងការពារសន្តិសុខដល់ប្រជាជននៃរាល់ប្រទេសនីមួយៗ ជាហេតុដែលបង្កឱ្យមានការវាយសង្រ្គប់លើលីប៊ី និងបង្ហឹកបង្ហិនកម្លាំងពលរដ្ឋ បិនហ្គាហ្វី ឱ្យក្លាយជាទ័ពរំដោះលីប៊ីទៀតផង ។

ក្នុងការជួបប្រជុំ "G-8" នេះលោក អូបាម៉ា បានសម្ដែងការរារែកពុំចង់ឱ្យមានក្រុម GI´s អាមេរិកាំងជាប់ផុងលើដីលីប៊ីទៀតឡើយ ដោយពុំបានបញ្ជាក់ឱ្យច្បាស់សម្រាប់ការសម្រេចរបស់បក្សសម្ព័ន្ធ NATO ពិសេស កាំប្រោន នាយករដ្ឋមន្ត្រី កាំរ៉ោន និង សាកូហ្ស៊ី ។ ទីបំផុត ដាវីតកាំរ៉ោន បានសុំឱ្យលើកយកទៅពិចារណាម្ដងទៀត ក្រោយពីបានឃើញភាពស្ទាក់ស្ទើររបស់ អូបាម៉ា ។

រីឯប្រទេសស៊ីរី ដែលដាក់ខ្លួនដូចសត្វដង្កូវកកេរស្លឹកឈើពុំមានសម្លេងនោះ ក៏ប្រធានាធិបតីស៊ីរីនេះកំពុងស្ថិតក្នុងការលួចសម្លាប់រង្គាលលើប្រជាជនរបស់ខ្លួន ដោយប្រើអាវុធ និងធ្វើទារុណកម្មយ៉ាងសម្ងាត់លើក្រុមបាតុករ ដែលគេចាប់យកទៅឃុំឃាំងមកសម្លាប់ចោល ។ ក្នុងករណីនេះ G-8 បាននាំគ្នាធ្វើសេចក្ដីព្រមានមួយ ដែលមានលក្ខណៈឱនលំទោនបំផុត ខ្លាចក្រែងរបបផ្ដាច់ការចុងក្រោយនេះពុំទទួលយកបាន ។ សុំកុំភ្លេចថា ប្រធានាធិបតីស៊ីរី បានទូរស័ព្ទទៅ ម៉េដវេហ្វ ប្រធានាធិបតីរុស្ស៊ី មុនបន្តិចដែល ម៉េដវេហ្វ ហោះហើរទៅប្រជុំ G-8 នៅប្រទេសបារាំង ។ G-8 ទាមទារឱ្យស៊ីរី គោរពសិទ្ធិបញ្ចេញមតិ ដែលត្រូវគោរពដោយរដ្ឋាភិបាលស៊ីរីតែម្ដង ។

ស្ដីពីករណីជនជាតិប៉ាឡេស្ទីនវិញនោះ ក្រោយពីមានសេចក្ដីថ្លែងការណ៍មួយធ្វើដោយសេតវិមានកាលពីសប្ដាហ៍មុន G-8 ដែលចង់ឱ្យអ៊ីស្រាអែលត្រឡប់មកសេវាព្រំដែនឆ្នាំ១៩៦៧នោះ គេឃើញមានប្រជាជនប៉ាឡេស្ទីន លោតកញ្ច្រោលទាមទារព្រំដែនកាលពីឆ្នាំ១៩៤៨ទៅវិញ ។

ពាក់ព័ន្ធទៅនឹងស៊ីរី គេសង្កេតឃើញបណ្ដាមតិជនជាតិលីបង់មួយចំនួន ចេញមុខគាំទ្រ ជួយឈឺឆ្អាលដល់ប្រជារាស្ត្រស៊ីរី ដែលភៀសខ្លួនគេចពីការសម្លាប់និងចាប់ចងក្នុងប្រទេសគេ រត់គេចចូលជ្រកកោនក្នុងទឹកដីព្រំប្រទល់លីបង់ជាប់នឹងស៊ីរី ។

គេសង្កេតឃើញមានការពឹងអាស្រ័យដ៏សំខាន់មួយដែល G-8 ពិសេសបារាំង អង់គ្លេស និង អូបាម៉ា បានដាក់ចិត្តសង្ឃឹមលើ ម៉េដវេហ្វ ក្នុងការបើកការចរចារទាំងជាមួយស៊ីរី ទាំងជាមួយហ្គាដាហ្វី ថ្វីត្បិតម៉េដវេហ្វ បានរំលឹកថា ហ្គាដាហ្វី ត្រូវតែដេញចេញពីអំណាចយ៉ាងណាក៏ដោយ ។ រហូតមកសព្វថ្ងៃនេះ គេសម្គាល់ឃើញថា របបផ្ដាច់ការហាក់កំពុងអង្គុយលើកៅអីខ្លួន ក្រោមម្លប់ជ្រៃក្រឹមដ៏ត្រជាក់ត្រជុំមួយ ។ បាន គីមូន និយាយថា (សម្ភាសន៍ផ្ដល់ឱ្យកាសែត Le Mouch) "សហគមន៍អន្តរជាតិចង់ឃើញរបបលីប៊ី ផ្ដល់សេចក្ដីសុខក្សេមក្សាន្តដល់ប្រជាជនខ្លួនឱ្យពិតប្រាកដ... អង្គការសហប្រជាជាតិ មានបំណង៤យ៉ាងគឺ : - ការឈប់បាញ់គ្នាភ្លាមៗ និងពិតប្រាកដ - ការបញ្ចូលអង្គការមនុស្សធម៌ -ការចរចារផ្លូវទូតជាបន្ទាន់ ដើម្បីពង្រឹងសន្តិភាពក្នុងតំបន់..." ។ ស្ដីពីលីបង់ លោក បាន គីមូន ទទួលរ៉ាប់រងថា "អង្គការសហប្រជាជាតិ និងចេញមុខសិក្សាពិនិត្យករណីលីបង់នៅខែកញ្ញាខាងមុខ ក្នុងការបង្កើតការឈប់បាញ់គ្នាដោយបង្កើតលទ្ធភាពថ្មីឱ្យមានការបោះឆ្នោតទទួលស្គាល់រដ្ឋប៉ាឡេស្ទីនច្បាស់លាស់ ។ នេះគឺការបញ្ចៀសការតទល់មុខគ្នា តាមរយៈការទូតដែលពុំត្រូវមានជាចាំបាច់ទេ" ៕


## ក្រុមហ៊ុន ទេសចរណ៍
## CENTURY TRAVEL & SERVICE CENTER

904 South 8th Street. Philadelphia, PA 19147
Tel : 215-625-2889; Fax : 215-625-9395
Cell : 267-934-9888; Email : centuryphl@yahoo.com

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុង និងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

- Serve all Airlines
- Domestic & Intl. flights
- Tour Arrangements
- Passport Extension
- Khmer Laissez- Passer
- Immigration
- Tourist Visa
- Notary Public

OFFICE Hours :
Mon - Sat 10:00 A.M - 6:00 P.M
Sun : 12:00 P.M - 5:00 P.M

We Speak Khmer, Chinese, Vietnamese
យើងនិយាយភាសាខ្មែរ ភាសាចិន វៀតណាម

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ អង្គរ




ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ សេវាអន្តោប្រវេសន៍
សេវាលិខិតឆ្លងដែន កក់សណ្ឋាគារ ឬជួលឡាន

USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

Cambodia Office: Victory Travel (Skin Belle)
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR,CHINA, ASIANA KOREAN AILINES

# ញត្តិគាំទ្រគណបក្សសិទ្ធិមនុស្សប្រចាំរដ្ឋ Pennsylvania សហរដ្ឋអាមេរិក

*លោក វ៉ា សាមុន ប្រធានសាខាគណបក្សសិទ្ធិមនុស្សប្រចាំរដ្ឋផែនស៊ីវេនា បានចេញសេចក្តីថ្លែង-ការណ៍ប្រឆាំងនឹងការផ្សាយខ្សែអាត់សម្ងាត់របស់លោក ហ៊ុន សែន និងលោក កឹម សុខា កាលពីថ្ងៃទី ៨ ខែមិថុនា ឆ្នាំ២០១០ យ៉ាងនេះថា :*



លោក វ៉ា សាមុន

"ការវិឡ្សន៍ទៅមុខរបស់គណបក្សសិទ្ធិមនុស្សបានធ្វើឱ្យគណបក្សប្រជាជនកម្ពុជា ជាពិសេស គឺលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងបរិវារមានការភ័យព្រួយចំពោះប្រជាប្រិយភាពរបស់គណបក្សសិទ្ធិមនុស្សនេះ ហើយទើបពួកគេបង្កើតជាល្បិចដ៏សែនគម្រក់មួយ ដើម្បីបំភ័ណ្ឌមតិមហាជនក្នុងគោលបំណងបង្ខូចកេរ្តិ៍ឈ្មោះដល់គណបក្សសិទ្ធិមនុស្ស ថាជាបក្សមួយដែលត្រូវបានបង្កើតឡើងដោយគណបក្សប្រជាជនកម្ពុជា និងដែលជាអាយ៉ងរបស់គណបក្សកុម្មុយនីស្តផ្តាច់ការប៉ុណ្ណោះ។

បងប្អូនជនរួមជាតិជាទីរាប់អាន!តាមរយៈខ្សែអាត់នៃការសន្ទាគ្នាអស់រយៈ២៤នាទីរវាង លោក កឹម សុខា ជាមួយលោក ហ៊ុន សែន កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧កន្លងមកហើយនោះ ដែលបក្សពួកកុម្មុយនិស្តចាត់ទុកថា ជាឯកសារសម្ងាត់ ហើយត្រូវបានទម្លាយចេញជាសាធារណៈកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១១ថ្មីៗកន្លងមកនេះ គឺពុំមានឃ្លាឬប្រយោគណាមួយដែលត្រូវបានកំណត់ថា គណបក្សសិទ្ធិមនុស្សបានបង្កើតឡើងដោយគណបក្សប្រជាជនកម្ពុជា ឬលោក កឹម សុខា ជាអាយ៉ងរបស់ហ៊ុន សែន នោះឡើយ ហើយពុំឃើញមានឃ្លាត្រង់ណាអះអាងដែរថា លោក កឹម សុខា ធ្លាប់បានទទួលលុយពីលោក ហ៊ុន សែន នោះផងទេ ក៏ប៉ុន្តែចំណុចដែលគួរឱ្យកត់សំគាល់វិញនោះ គឺលោក ហ៊ុន សែន ទេតើ ដែលជាអ្នកហៅទូរស័ព្ទមករកលោក កឹម សុខា ហើយក៏បានលួចថតសម្លេងជាសម្ងាត់ ដោយគ្មានការអនុញ្ញាតិអំពីសាម៉ីខ្លួនគេទាល់តែសោះ នេះគឺជាអំពើរមួយខ្វះសុជីវធម៌ ហើយនឹងខុសច្បាប់ទាំងស្រុងដែលមិនអាចទទួលយកជាការបានឡើយ ។

ក្នុងដំណើរទស្សនកិច្ចមកកាន់សហរដ្ឋអាមេរិកជាញឹកញាប់ លោក កឹម សុខា តែងតែបង្ហើបប្រាប់សកម្មជនបានដឹងអំពីការជួបតាមទូរស័ព្ទរវាងលោកជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជារឿយៗរួចស្រេចទៅហើយ វាពិតជាគ្មានអ្វីដែលជាអាថ៌កំបាំងសោះឡើយ ។ ល្បិចកល់ដ៏សែនក្រខ្វក់ថោកទាបរបស់គណបក្សប្រជាជនកម្ពុជាបែបនេះ ពុំត្រូវបានសាធារណៈមតិចាប់អារម្មណ៍នោះទេ តែផ្ទុយទៅវិញធ្វើឱ្យគណបក្សសិទ្ធិមនុស្សកាន់តែមានប្រជាប្រិយ-ភាព និងសេចក្តីថ្លៃថ្នូរថែមទៀតផង។

ជាទីបញ្ចប់សាខាគណបក្សសិទ្ធិមនុស្សប្រចាំរដ្ឋផែនស៊ីលវ៉ាន់ញ៉ា សហរដ្ឋអាមេរិក សូមប្រឆាំងយ៉ាងដាច់ខាតចំពោះល្បិច"ស្វាស៊ីបាយយកទៅលាបមាត់ពពែ"របស់គណបក្សប្រជាជនកម្ពុជា ថែមទៀត និងផ្តល់នូវកម្លាំងចិត្តចំពោះឯកឧត្តម កឹម សុខា តទៅទៀត ក្នុងគោលបំណងធ្វើការផ្លាស់ប្តូរនៃរបបដឹកនាំពីលទ្ធិកុម្មុយនីស្តផ្តាច់ការមកជាលទ្ធិប្រជាធិបតេយ្យជូនប្រទេសកម្ពុជាឱ្យទាល់តែបានជាដាច់ខាត ៕

(តមកពីទំព័រទី ២០)

## លឹម ហ្គុតុង ពីកម្មករ...

ផលិតក្រដាស ផលិតថាមពលអគ្គិសនីរុករកឧស្ម័ន និង ប្រេង ។ លោក លឹម បានផ្ទេរតំណែងប្រធានក្រុមហ៊ុន "Genting Group" ទៅឲ្យកូនប្រុសរបស់គាត់ឈ្មោះ តាន់ស្រ៊ីលឹម កុកថាយ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ។

លោក លឹម ហ្គុតុង ទទួលមរណភាពនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៧ ដោយជំងឺដុះសាច់ក្នុងលំពែង និងជំងឺសរសៃឈាមបេះដូងនៅក្នុងមន្ទីរពេទ្យស៊ូបាងចាយ៉ា ដោយបន្សល់ទុកភរិយាឈ្មោះអ្នកស្រី លី គឹមហួ កូន៦នាក់ និងចៅប្រុសស្រីចំនួន១៩នាក់ ។ សពរបស់គាត់ត្រូវបានបញ្ចុះនៅឧទ្យានអនុស្សាវរីយ៍ ហ្គុតុង ក្នុងបុរី ហ្គុតុងចាយ៉ា នៅថ្ងៃច័ន្ទ ទី២៩ ខែតុលា ឆ្នាំ២០០៧ ។

ភ្ញៀវជាង២ម៉ឺននាក់បានចូលរួម មានតាំងពីរាជ-វង្សានុវង្ស មហាសេដ្ឋីធ្វើមៗនៅអាស៊ី អ្នកនយោបាយ មិត្តភ័ក្តិដៃគូពាណិជ្ជកម្មសាធារណជននានា បានចូលរួមកំដរពិធីបុណ្យសពលោក លឹម ហ្គុតុង ព្រមទាំងកម្រងផ្កា និងសារសម្តែងសមានចិត្តចំពោះសព ។

កម្រងផ្កាជាង១០០០កម្រងតម្រៀបគ្នាប្រវែង ៣០០ម៉ែត្រ តាមផ្លូវចូលភូមិគ្រឹះរបស់លោក លឹម ផ្ញើពីគ្រប់ទីកន្លែងក្នុងពិភពលោក រួមមានកាស៊ីណូ ឡាសវេហ្គា, សេដ្ឋីស្តេនលីហូ នៅកាស៊ីណូម៉ាកាវ, អភិបាលខេត្ត ហ្វុជៀន ប្រទេសចិន ទីកន្លែងលោក លឹម បានកើត, មហាសេដ្ឋីលេខ២របស់ទ្វីបអាស៊ី លោកលីកាស៊ីង ដែល (បច្ចុប្បន្នជាមហាសេដ្ឋីទី១) បានផ្ញើសាររំលែកទុក្ខចំពោះគ្រួសារសព និងពាក្យពេចន៍ប្រកបដោយខ្លឹមសារចំពោះលោក លឹម ៕

***ឈុនឡេង***



**Business for sale**
**Lowell City Video**



Lowell City Video
32-38 Branch St., Unit #5,
Lowell, MA 01851

For more information contact:
Ms. Sokha 978.452.4500 or 978.996.6921

**Business For Sale**

**លក់ហាងលក់ភេសជ្ជៈនៅរីវៀ**




ដើម្បីព័ត៌មានបន្ថែមសូមទាក់ទង
Hanna: 781.535.8625 ឬ
Hong : 617.780.1019
**អាសយដ្ឋាន : អូរ៉េងហ្គ្រ ហ្គ្រូម៉ាកិត**
**Orange Grove Market**
**(Beer, Wine, Grocery, Lottery)**
**158 Shirley Ave, Revere, MA 02151**

# ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី១០ ខែមិថុនា ឆ្នាំ២០១១


# K Speu Clash Sees Villagers, Police Injured

BY KUCH NAREN
THE CAMBODIA DAILY

At least seven protesters and three police officers were seriously injured yesterday in a 15-minute confrontation in Kompong Speu's Odong district during which police and military police opened fire to break up a land dispute demonstration, human rights workers and villagers said.

Human rights workers from the organizations Adhoc and Licadho who were present said two police officers and a military police officer were seriously injured and brought to the provincial referral hospital after protesters armed with knives, axes and bamboo sticks confronted the armed forces.

More than 400 protesters blocked Road 51 in Phnom Touch commune for about nine hours, causing a kilometer-long traffic jam before the fighting erupted. Han Ny, a representative of the protesters, said the armed forces had fired about 50 shots into the ground, air and toward the protesters, injuring two, while five others were beaten and shocked with electric batons.

Mr Ny said that more than 500 police, military police and RCAF soldiers led by provincial prosecutor Khut Sopheang had employed lethal force against the protesters, who were demonstrating over a disputed 65 hectares of land claimed by Meng Keth Company, which is owned by Taiwanese businessman Chang Kuo Sheng.

At issue is the legality of a land title acquired in 1997 by Mr Chang, who was only naturalized as a Cambodian citizen 10 years ago. Foreigners are prohibited from owning land.

"These cruel armed forces are colluding with court officials to grab our land to give to a rich Taiwanese guy, and they were not hesitant in firing at us," Mr Ny said.

Mr Sopheang and Chan Da, deputy commander of the provincial military police, said a number of armed forces members had been injured in the clash.

**CORRECTION:** Due to an editorial error, yesterday's brief on Tuesday's friendly football match between Cambodia and Malaysia (page 22) incorrectly said the Cambodian players were under 23. Cambodia's senior men's team took the field against the Malaysian under-23s.

"But I can clarify that the competent forces never shot at the villagers," Mr Da said, declining to comment further.

Am Sam Ath, technical supervisor at Licadho, said his organization was treating the injured protesters, two of whom had been shot in the arms, legs and feet. He said one military police officer sustained ax wounds to his hips, while another sustained a serious head wound.

"But I don't think the armed last year. This also resulted in clashes between villagers and the armed forces.

"The verdict is unjust, because there are a lot of irregularities over the issuance of the land title for the Taiwanese businessman," Mr Bun Chhuon said.

"We blocked the road because we want to protect our land," he added.

Contact information for Mr Chang was not available yesterday.

Contacted by telephone yesterday, Ky Dara, a former Meng Keth representative, said he had sold his 10-percent stake in the company months ago and declined to comment on yesterday's violence, but he said the land was bought legally in 1997.

forces aimed into the crowd, otherwise it would have been a terrible tragedy," he said.

Rath Thavy, a provincial investigator for Adhoc, said: "Whatever court officials and armed forces did, it was just to win. It doesn't matter to them if they confront and injure the villagers; they don't have to discuss the issue with the affected families."

Sun Bun Chhuon represents 88 families from three communes in Kandal and Kompong Speu provinces who claim to have used the land since 1979. He said the villagers would continue to contest a Dec 31, 2009, Supreme Court verdict awarding the land to Mr Chang. The first attempt to enforce the verdict was in March clashes between villagers and the armed forces.

"The verdict is unjust, because there are a lot of irregularities over the issuance of the land title for the Taiwanese businessman," Mr Bun Chhuon said.

"We blocked the road because we want to protect our land," he added.

Contact information for Mr Chang was not available yesterday.

Contacted by telephone yesterday, Ky Dara, a former Meng Keth representative, said he had sold his 10-percent stake in the company months ago and declined to comment on yesterday's violence, but he said the land was bought legally in 1997.

# ការប៉ះទង្គិចគ្នានៅខេត្តកំពង់ស្ពឺបណ្តាលឱ្យអ្នកភូមិនិងមន្ត្រីនគរបាលរងរបួស

ដោយ : គុច ណារ៉េន
THE CAMBODIA DAILY

បុគ្គលិកសិទ្ធិមនុស្សនិងក្រុមអ្នកភូមិបាននិយាយថា យ៉ាងហោចណាស់មានអ្នកតវ៉ា៧នាក់ និងមន្ត្រីនគរបាល៣នាក់បានរងរបួសធ្ងន់កាលពីម្សិលមិញ នៅក្នុងការប្រឈមមុខដាក់គ្នារយៈពេល១៥នាទី នៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដែលពេលនោះនគរបាល និងកងរាជអាវុធហត្ថបានបាញ់កាំភ្លើង ដើម្បីបំបែកបាតុកម្មពាក់ព័ន្ធជម្លោះដីធ្លីមួយ ។

បុគ្គលិកសិទ្ធិមនុស្សមកពីអង្គការអាដហុក និងអង្គការលីកាដូ ដែលមានវត្តមាននៅទីនោះ បាននិយាយថា មន្ត្រីនគរបាល២នាក់ និងមន្ត្រីកងរាជអាវុធហត្ថម្នាក់បានរងរបួសធ្ងន់ ហើយត្រូវបាននាំទៅមន្ទីរពេទ្យបង្អែកខេត្ត បន្ទាប់ពីក្រុមអ្នកតវ៉ាប្រដាប់ដោយ កាំបិទ ពូថៅ និងដំបងឬស្សី បានប្រឈមមុខជាមួយកម្លាំងប្រដាប់អាវុធ ។

ដោយបដិសេធមិនធ្វើអត្ថាធិប្បាយបន្ថែមលោក ចាន់ ដា បានមានប្រសាសន៍ថា "ប៉ុន្តែខ្ញុំអាចបញ្ជាក់បានថា កម្លាំងសមត្ថកិច្ចមិនដែលបាញ់អ្នកភូមិទេ" ។

លោក អំ សំអាត អ្នកគ្រប់គ្រងបច្ចេកទេសនៅអង្គការលីកាដូ បានមានប្រសាសន៍ថា អង្គការរបស់លោកកំពុងតែព្យាបាលអ្នកតវ៉ាដែលរងរបួស ដែល២នាក់នៅក្នុងនោះត្រូវបានបាញ់ចំដៃ ជើង និងប្រអប់ជើង ។

លោកបានមានប្រសាសន៍ថា មន្ត្រីកងរាជអាវុធហត្ថម្នាក់បានរងរបួលត្រង់ត្រគាកដោយសារពូថៅ ចំណែកឯមន្ត្រីម្នាក់ទៀតរងរបួសធ្ងន់ធ្ងរ ។

លោកបានមានប្រសាសន៍ថា "ប៉ុន្តែខ្ញុំមិនគិតថា កម្លាំងប្រដាប់អាវុធបានតម្រង់ទៅក្រុមមនុស្សទេ ព្រោះបើដូច្នេះមែនវាបណ្តាលឱ្យមានសោកនាដកម្មដ៏គួរឱ្យរន្ធត់បាត់ទៅហើយ" ។

រ័ត្ន ថាវី ជាអ្នកស៊ើបអង្កេតប្រចាំខេត្តនៅអង្គការអាដហុក



ប្រជាពលរដ្ឋវាយបកទៅក្រុមប៉ូលីសវិញ ដើម្បីការពារដីស្រែរបស់ខ្លួន

ក្រុមអ្នកតវ៉ាជាង៤០០នាក់បានបិទផ្លូវលេខ៥១ ក្នុងឃុំភ្នំតូច អស់រយៈពេលប្រហែល៩ម៉ោង ដោយធ្វើឱ្យស្ទះចរាចរណ៍ចម្ងាយ១គីឡូម៉ែត មុនពេលការប៉ះទង្គិចបានផ្ទុះឡើង ។

លោក ហ៊ាន់ នី ជាតំណាងក្រុមអ្នកតវ៉ា បាននិយាយថា កម្លាំងប្រដាប់អាវុធបានបាញ់ប្រហែល៥០គ្រាប់ទៅលើដីឡើងលើ និងសំដៅក្រុមអ្នកតវ៉ា ដោយធ្វើឱ្យរងរបួសមនុស្ស២នាក់ ចំណែកឯមនុស្ស៥នាក់ផ្សេងទៀតត្រូវបានវាយ និងឆក់ដោយដំបងឆក់ ។

លោក ហ៊ាន់ នី បាននិយាយថា នគរបាល កងរាជអាវិធហត្ថ និងទាហានកងយោធពលខេមភូមិន្ទជាង៥០០នាក់ ដែលដឹកនាំដោយលោក ឃុត សុភាង ជាព្រះរាជអាជ្ញាអមតុលាការខេត្តបានប្រើកម្លាំងប្រកបដោយគ្រោះថ្នាក់ប្រឆាំងនឹងក្រុមអ្នកតវ៉ា ដែលធ្វើបាតុកម្មតវ៉ាអំពីដីដែលមានទំនាស់ទំហំ៥ហិកតា ដែលអះអាងកាន់កាប់ដោយក្រុមហ៊ុន ម៉េង កេត ដែលកាន់កាប់ដោយលោក ចាង គួសេង ជាអ្នកជំនាញតៃវ៉ាន់ ។

បញ្ហាគឺស្ថិតនៅត្រង់ភាពស្របច្បាប់នៃប័ណ្ណកម្មសិទ្ធិដីមួយដែលលោក ចាង គួសេង ទទួលបានកាលពីឆ្នាំ១៩៩៧ ដែលលោកបានចូលសញ្ជាតិកម្ពុជា កាលពី១០ឆ្នាំមុន ។ ជនបរទេសត្រូវហាមឃាត់មិនឱ្យកាន់កាប់ដីធ្លីទេ ។

លោក ហ៊ាន់ នី បាននិយាយថា "កម្លាំងប្រដាប់អាវុធឃោរឃៅទាំងនេះបានឃុបឃិតជាមួយក្រុមមន្ត្រីតុលាការចាប់យកដីរបស់ពួកយើញដើម្បីប្រគល់ឱ្យជនជាតិតៃវ៉ាន់ ជាអ្នកមានម្នាក់នេះ ហើយពួកគេមិនរារែកក្នុងការបាញ់សំដៅមកលើពួកយើងទេ" ។

លោក ឃុត សុភាង និងលោក ចាន់ ដា ជាមេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត មានប្រសាសន៍ថា កម្លាំងប្រដាប់អាវុធមួយចំនួនបានរងរបួលនៅក្នុងការប៉ះទង្គិចនេះ ។

បានមានប្រសាសន៍ថា "អ្វីក៏ដោយដែលក្រុមមន្ត្រីតុលាការ និងកម្លាំងប្រដាប់អាវុធធ្វើ គឺគ្រាន់តែដើម្បីយកឈ្នះតែប៉ុណ្ណោះ។ ពួកគេមិនខ្វល់រឿងប្រឈមមុខនិងធ្វើឱ្យក្រុមអ្នកភូមិរងរបួសនោះទេ ។ ពួកគេមិនព្រមពិភាក្សាបញ្ហាទាំងនេះជាមួយគ្រួសារប្រជាពលរដ្ឋដែលរងផលប៉ះពាល់ឡើយ" ។

លោក ស៊ុន ប៊ុនជួន តំណាងឱ្យប្រជាពលរដ្ឋ៨៨គ្រួសារមកពីឃុំចំនួន៣ ក្នុងខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ ដែលអះអាងថា បានប្រើប្រាស់ដីនេះចាប់តាំងពីឆ្នាំ១៩៧៩មក ។

លោកបាននិយាយថា ក្រុមអ្នកភូមិនឹងបន្តធ្វើការតវ៉ាចំពោះសាលដីការបស់តុលាការកំពូលចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រគល់ដីនេះទៅឱ្យលោក ចាង គួសេង ។ ការព្យាយាមលើកដំបូង ដើម្បីអនុវត្តសាលដីកានេះ គឺធ្វើឡើងកាលពីខែមីនាឆ្នាំមុនដែលការអនុវត្តនេះក៏បានបណ្តាលឱ្យមានការប៉ះទង្គិចគ្នារវាងក្រុមអ្នកភូមិ និងកងរាជអាវុធហត្ថផងដែរ ។

លោក ស៊ុន ប៊ុនជួន បាននិយាយថា "សាលដីកានេះមិនយុត្តិធម៌ទេ ពីព្រោះមានភាពមិនប្រក្រតីច្រើនជុំវិញការចេញប័ណ្ណកម្មសិទ្ធិដីដល់អ្នកជំនាញតៃវ៉ាន់រូបនេះ" ។ លោកបានបន្ថែមថា "យើងបិទផ្លូវ ព្រោះយើងចង់ការពារដីរបស់យើង" ។

មិនមានព័ត៌មានសម្រាប់ទាក់ទងលោក ចាង គួសេង ទេកាលពីម្សិលមិញ ។ ដោយត្រូវបានទាក់ទងតាមទូរស័ព្ទកាលពីម្សិលមិញលោក គី តារា ជាអតីតតំណាងក្រុមហ៊ុន ម៉េង កេត បានមានប្រសាសន៍ថា លោកបានលក់ភាគហ៊ុន១០ភាគរយរបស់លោកនៅក្នុងក្រុមហ៊ុននេះជាច្រើនខែមកហើយ ហើយបានបដិសេធមិនធ្វើអត្ថាធិប្បាយអំពីអំពើហិង្សាកាលពីម្សិលមិញទេ ប៉ុន្តែលោកបានមានប្រសាសន៍ថា ដីនេះត្រូវបានទិញដោយស្របច្បាប់កាលពីឆ្នាំ១៩៩៧ ៕

# បញ្ចុះទម្ងន់ងាយស្រួលដូចបកចេក !



ម៉ូនីកា យ៉ាន ម៉ារីយ៉ាណា ជូលីយ៉ា

•••ខ្ញុំចង់ចែករំលែកបទពិសោធន៍ថ្មីៗរបស់ខ្ញុំស្ដីពីទម្ងន់ដែលចេះតែកើនមិនព្រមចុះវិញសោះ ស្រាប់តែខ្ញុំអាចធ្វើឱ្យស្រកបានអស់១៥ផោន ក្នុងរយៈពេល១២អាទិត្យយ៉ាងងាយស្រួលមិនគួរឱ្យជឿ ។

ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ជម្ងឺប្រចាំកាយបានផុសចេញច្រើនមុខ មានលើកសម្ពាធឈាម មានខ្លាញ់កូឡេស្តេរុល មានទាំងទឹកនោមផ្អែម នេះដោយសារតែទម្ងន់ដែលចេះតែកើនឡើងរហូតដល់ជាង២១០ផោនទៅហើយ ហើយវេជ្ជបណ្ឌិតរំលឹកខ្ញុំដដែលៗថា ឱ្យបញ្ចុះទម្ងន់ ហាត់ប្រាណ បន្ថយម្ហូបមានខ្លាញ់ច្រើន ។ ខ្ញុំមានការធុញទ្រាន់នឹងលេបថ្នាំចេះតែច្រើនទៅៗ បង្អត់ម្ហូបដែលមានរសជាតិឈ្ងុយឆ្ងាញ់ ហាត់ប្រាណហាត់ស្ទើរដាច់ខ្យល់ ។ ជម្រុញដោយសុបិនដែលជាភរិយារបស់ខ្ញុំបានធ្វើឱ្យខ្ញុំសម្រេចចិត្តចូលរួមកម្មវិធីបញ្ចុះទម្ងន់មួយនៅជ្រុងផ្លូវលេខ៧ និងបេនប្រ៊ីត ឈ្មោះ Art of Wellness ពីព្រោះខ្ញុំដឹងថា ពុំអាចធ្វើទម្ងន់ឱ្យចុះដោយឯកឯងបានទេ ទោះបីជាមានសៀវភៅជំនួយក៏ដោយ ហើយនៅទីនោះមានអ្នកឯកទេសជាខ្មែរ និងចិនធ្វើឱ្យខ្ញុំមានការកក់ក្ដៅខ្លះដែរ ព្រោះវប្បធម៌ដូចគ្នា ។ ខ្ញុំក៏បានចូលក្នុងក្រុមមួយមានគ្នាបីនាក់ ដែលរៀងរាល់សប្ដាហ៍យើងត្រូវតែជួបគ្នា ដើម្បីចែករំលែកបទពិសោធន៍ដែលបានប្រទះនាអាទិត្យកន្លងមកហើយនោះ ។ យូលីយ៉ា ជាអ្នកធ្លាប់បានបញ្ចុះទម្ងន់បានជាង ២០ផោន កាលពីប៉ុន្មានឆ្នាំមុន ហើយនៅរក្សាទម្ងន់ទាបបានល្អរហូតដល់ថ្ងៃនេះ ជាអ្នកណែនាំកម្មវិធីជាមួយ យ៉ាន ជាបណ្ឌិតកម្មវិធី និងជានាយកមជ្ឈមណ្ឌល ។


ពិន សំខុន ម៉ារីយ៉ាណា ម៉ូនីកា ជេសុន

ថ្ងៃដំបូងនៃការជួបគ្នាខ្ញុំមានការភ្ញាក់ផ្អើល ដោយបានឮដៃគូ ជេសុន នៃក្រុមយើងនិយាយថា : "ខ្ញុំបញ្ចុះទម្ងន់បាន ៥០០ផោន ហើយក្នុងរយៈពេល៩ខែ" ហើយខ្ញុំត្រូវបញ្ចុះវាតទៅទៀត" និយាយផង មាត់ទំពារផ្លែផោមយ៉ាងឆ្ងាញ់ឮគ្រួបៗនាព្រលប់ម៉ោង៧ហើយនោះ រួចបន្តថា "ខ្ញុំបានសាកល្បងច្រើនកន្លែងហើយ ដើម្បីបញ្ចុះទម្ងន់របស់ខ្ញុំ ៨០០ផោន ទើបតែបានទទួលលទ្ធផល នាពេលនេះនៅកន្លែងនេះ" និយាយផងអរគុណយ៉ានផង ដែលបានណែនាំខ្លួនចង់បន្តកម្មវិធីបញ្ចុះទម្ងន់ដោយរីករាយ និងដោយចំណេះ។ ចំណែកខ្ញុំ និង ម៉ារីយ៉ាណា ជាសិស្សថ្មីមានការលំបាក និងបង្អត់ម្ហូបដ៏ឈ្ងុយឆ្ងាញ់ទាំងឡាយ ដែលបានបង្ហាញខ្លួនពីមុខយើង គ្រប់វេលានោះណាស់ ។

បច្ចេកទេសនៃការបញ្ចុះទម្ងន់ គឺស្ថិតនៅលើការយល់អំពីចំណីដែលយើងបរិភោគ ហើយនៅពេលហូបទៅហើយ យើងអាចដឹងថា ចំណីនោះវានឹងមានសកម្មភាពរបៀបណានៅក្នុងខ្លួនយើង ថាតើវិធីដែលយើងបានធ្វើកន្លងមកហើយត្រឹមត្រូវដែរឬទេ? គ្រាន់តែ១អាទិត្យដំបូងនៃកម្មវិធី "លាងសំអាតក្នុងខ្លួន" (Detox) ខ្ញុំចុះទម្ងន់៤-៥ផោនទៅហើយ ដោយបរិភោគបន្លែ ផ្លែឈើ និងផឹកទឹកឱ្យបានច្រើន មានថ្នាំលេប និងផឹកទឹកក្រូចឆ្មាផង... រហូតដល់៥ទៅ៦សប្ដាហ៍ ទើបទម្ងន់ខ្ញុំធ្លាក់ចុះក្រោម២០០ផោនយ៉ាងលំបាក ពីព្រោះខ្ញុំរវល់ខ្លាំងពេក ហើយហូបមិនសូវស្របនឹងកម្មវិធីគេផង ក៏ប៉ុន្តែសប្បាយចិត្តណាស់ ពីព្រោះទម្ងន់នេះឡើងលើស២១០ផោននោះយូរណាស់ទៅហើយ" ធ្វើយ៉ាងណាក៏មិនព្រមចុះថយសោះ យើងសម្រេចចិត្តជប់លៀងម្ហូបឆ្ងាញ់ម្ដង ហើយដាច់សីល១ថ្ងៃនោះទៀតទៅ ។ ផ្នែកមួយទៀតនៃបច្ចេកទេសនោះគឺការហាត់ប្រាណដែលអ្នកបង្ហាត់របស់យើងឈ្មោះ ម៉ូនីកា នាងបង្ហាត់បច្ចេកទេសនៃចលនាធម្មតារៀងរាល់ថ្ងៃរបស់យើងឱ្យក្លាយទៅជាការហាត់ ។ នាងបង្ហាត់១អាទិត្យបាន១ម៉ោង នាំឱ្យបែកញើសជោកខ្លួនហត់ស្ទើរដាច់ខ្យល់! ។ ការហាត់ប្រាណដែលជាគោលការណ៍សំខាន់ៗដែរនោះខ្ញុំពុំបានអនុវត្តគ្រប់គ្រាន់ទេ តែគ្រាន់តែធ្វើការងារដោយប្រើកម្លាំងកាយច្រើនតែប៉ុណ្ណោះ តែ ម៉ារីយ៉ាណា នាងបានដើរហាត់ប្រាណច្រើនម៉ោងក្នុងមួយអាទិត្យនៅខែចុងក្រោយនេះនាងថា "ចុះបាន២៥ផោនហើយ" ចំណែកឯខ្ញុំវិញ ទើបនឹងចុះបាន១៥ផោនតែប៉ុណ្ណោះ ។

